# សាសនានៅត្រង់ណា?

មុននិងថ្លាថ្លែងចែងជាកាព្យ    មានខុសជួយប្រាប់កុំឲ្យខាន
ដល់អស់អ្នកស្តាប់និងអ្នកអាន    មេត្តាតាមដានដូចតទៅ។

សាសនាគឺពាក្យប្រៀនប្រដៅ    ន័យល្អផ្អិនផ្អៅគួរគោរព
ដឹកនាំមនុស្សសត្វទាំងថ្ងៃយប់    ប្រាប់ថាឲ្យឈប់កុំធ្វើបាប។

ជាតិខ្មែរធ្លាប់តែមានជំនឿ    ដាក់កាយចិត្តជឿលើព្រះពុទ្ធ
ដឹកនាំសាសនាល្អបរិសុទ្ធ    នាំសត្វរួចផុតពីទុក្ខា។

មកដល់ពេលនេះក៏ឃើញច្បាស់    ខ្មែរទាំងក្មេងចាស់ក្នុងរដ្ឋា
នៅតែគោរពជឿសាសនា    សែនហ៊ុនរាជការបញ្ញាបាន។

ង៉ែត-*វង្ស*លង់យសចុះ*អវីចី*    មានចិត្តអប្រិយហួសពីស្មាន
បញ្ញាលោកយួនឲ្យតាមដាន    នាំឲ្យរំខានសង្ឃប្រោសសត្វ។

សង្ឃល្អបរិសុទ្ធមានចិត្តជួយ    បរិស័ទមានព្រួយសង្ឃជួយដោះ
ជួយតាមអហិង្សាដោយចិត្តស្មោះ    តែត្រូវរងគ្រោះដោយជនពាល។

ជនពាលស៊ីពាលក្នុងរដ្ឋា    ពាលអាប់ប្រាជ្ញាចង់ល្បីឈ្មោះ
វាយលោកចាប់សង្ឃឲ្យរងគ្រោះ    ប៉ូលីសទុរយសចុះ*អវីចី*។

ជាតិនិងសាសនាដើរថយក្រោយ    មេកើយមេកោយបានការអី
ហេតុនេះសូមខ្មែរទាំងប្រុសស្រី    នាំគ្នាឃ្លាតខ្មីទាញកចុះ។

ទុកនាំអាប់យសដល់ជាតិខ្មែរ    សាសនាធ្លាប់ថៃក៏ធ្លាក់ចុះ
អំណាចបុណ្យសក្តិនិងកេរ្តិ៍ឈ្មោះ    *វង្ស*-ង៉ែតគិតចុះសាសនាអី?។

សាសនានាំមនុស្សឲ្យសុខសាន្ត    គោរពឲ្យបានល្អប្រពៃ
កុំយកមកប្តូរអំណាចលោកីយ    សាសនាជាអ្វីដែលមនុស្សជឿ។

ហឿង សុវណ្ណ    ថ្ងៃទី២៦ ខែឧសភា ព.ស.២៥៥៦ គ.ស.២០១២